[*unofficial translation*]

KINGDOM OF CAMBODIA
Nation Religion King

[*logo*]
Phnom Penh Court of Appeal

**Criminal Chamber Case File Number: 1255, dated 18 July 2024**
**Ruling No. 130 "ក្រIV ឧ.វ" Dated 22 August 2024**

**IN THE NAME OF THE KHMER PEOPLE**

**The Phnom Penh Court of Appeal**

The Criminal Chamber, established in accordance with the Law on Organization of the Judicial Bodies, promulgated by Royal Kram No. **NS/RK/0714/015, dated 16 July 2014**,

Opened a public hearing at the Phnom Penh Court of Appeal on **19 August 2014** with:

**<u>Composition of the Hearing Council</u>**

| | | |
|---|---|---|
| Mr. | **DUCH Soksarin**, | Council Chair |
| His Excellency | **You Bunna**, | Advisory Judge |
| Mr. | **Keo Mony**, | Advisory Judge |

**<u>Mandatory Prosecutor-General</u>**

His Excellency **Im Sophan**, Investigating Judge Deputy-General

**<u>Hearing Clerk</u>**

Mr. **Uch Kenbo**

To hear the appeal No. **109, dated 02 July 2024**, of **Horm Sunrith** and **Seng Reach**, attorneys defending the rights for the accused named **Chea Chan**, and the appeal No. **117, dated 17 July 2024**, of the accused, named **Duong Samnang**, appealing the criminal judgement No. **770 (ឧ), dated 20 June 2024**, of the Kompong Speu Provincial Court of First Instance, **on the item of the entire rulings**, pertaining:

1- The accused named **Chea Chan**, male, 40 years old, of Khmer origin, Buddhist, occupation: factory mechanic, born in Noreay village, Po Angkran commune, Borsith district, Kompong Speu province, residence before arrest in Noreay village, Po Angkran commune, Borsith district, Kompong Speu province, son of Mr. **In Sareth** "deceased", and Mrs. **Chhit Ly** "living", husband of Mrs. **Chhe Chanra**, with three children, a major, with no previous sentence; **(in detention)**

-**Order to detain No. 188 "ឈ", dated 18 February 2024, at the Kompong Speu provincial prison**;

Charged with **conspiracy to commit theft**, committed at the location of Wing Star Shoes footwear factory, located in Ang Sokunthea village, Moha Russey commune, Korng Pisey district, Kompong Speu province, during 2022, a criminal offense stipulated and punishable in accordance with provisions of Article 29, Article 353, and Article 356 of the Criminal Code;

[*stamp*]

- **Seng Reach and Hong Sambath, attorneys defending the rights for the accused named Chea Chan;**

2-The accused named **Duong Samnang**, male, born 1987, of Khmer origin, Buddhist, born in in Noreay village, Po Angkran commune, Borsith district, Kompong Speu province, residence before arrest in Noreay village, Po Angkran commune, Borsith district, Kompong Speu province, son of Mr. **Sim Tim** "living", and Mrs. **Sim Saroem** "living", husband of Mrs. **Dan Sreymom**, with 02 children, a major, with no previous sentence; **(escaped)**

**-Order to arrest No. 313 (ឱ), dated 20 June 2024, of the Hearing Judge of the Kompong Speu Provincial Court of First Instance;**

Charged with **theft**, committed at the location of Wing Star Shoes footwear factory, located in Ang Sokunthea village, Moha Russey commune, Korng Pisey district, Kompong Speu province, during 2022, a criminal offense stipulated and punishable in accordance with provisions of **Article 353, and Article 356 of the Criminal Code**;

- **Seang Rady, attorney defending the rights of the accused named Duong Samnag**

-**Civil petitioner**, named **Banh Siem Ann**, male, born 1954, of current residence in Village 2, Sangkat 3, Preah Sihanouk city, Preah Sihanouk province, representing Wing Star Shoe company;

**Matter of facts**

In 2022, at the location of Wing Star Shoes footwear factory, located in Ang Sokunthea village, Moha Russey commune, Korng Pisey district, Kompong Speu province, a case of **theft and conspiracy to commit theft** took place, caused by the accused named **Chea Chan**, male, 40 years old, and **Duong Samnang**, male, 37 years old. When the incident took place, **Duong Samnang** was stealing cooper of Wing Star Shoe footwear factory, with **Chea Chan** as the patrol. After the incident, the victim, named **Banh Siem Ann**, male, 70 years old, filed a complaint to the Kompong Speu Provincial Police Commissariat; the competent authorities then arrested the above accused and forwarded the case file to the Prosecution attached to the Kompong Speu Provincial Court of First Instance to take legal action.

-**Having seen** criminal judgement No. **770 (ឱ), dated 20 June 2024,** of the Kompong Speu Provincial Court of First Instance, with the contents of ruling as follows:

**1/.Sentenced:**

1.1-**Duong Samnang**, male, born 1987, to **1 (one)** year in prison for theft, committed at the location of Wing Star Shoe footwear factory, located in Ang Sokunthea village, Moha Russey commune, Korng Pisey district, Kompong Speu province, during 2022, a criminal offense stipulated and punishable in accordance with provisions of Article 353, and Article 356 of the Criminal Code.

1.2-**Chea Chan**, male, 40 years old, of the above identity, to **1 (one)** year in prison, but this sentence shall be implemented in prison for **6 (six) months** while the remainder suspended in accordance with the provisions on suspension of normal punishment of the Criminal Code on **conspiracy to commit theft**, committed at the location of Wing Star Shoe footwear factory, located in Ang Sokunthea village, Moha Russey commune, Korng Pisey district, Kompong Speu province, during 2022, a criminal offense stipulated and punishable in accordance with **Articles 29, 353, 356 of the Criminal Code**.

[*stamp*]

2-Cease the order to arrest No.: **93, dated 22 February 2024**, issued by the Investigating Judge and ordering arrest of **Duong Samnang**, male, born 1987, again;

This judgement was heard on **29 May 2024**, before the accused named **Chea Chan**, in default of the accused named **Duong Samnang**, in default of the civil petitioner and was publicly pronounced on **20 June 2024**, with an appeal authorized within the legal timeframe.

-**Having seen** copy of the appeal No.: **109, dated 02 July 2024**, of **Horm Sunrith**, and **Seng Reach**, attorneys defending the rights of the accused named **Chea Chan**, filing for an appeal against criminal judgement No.: **770 (ឧ), dated 20 June 2024**, of the Kompong Speu Provincial Court of First Instance, **on the item of the entire ruling**;

-**Having seen** copy of the Court of Appeal No.: **117, dated 17 July 2024**, of the accused named **Duong Samnang**, filing an appeal against the criminal judgement No.: **770 (ឧ), dated 20 June 2024**, of the Phnom Penh Capital Court of First Instance, **on the item of the entire ruling**;

-**Having seen** report on criminal case file of the reporting judge of the Court of Appeal;

-**Having seen** the conclusion of the mandatory prosecutor-general attached to the Court of Appeal.

**At the hearing:**

-The accused named **Chea Chan** (present)
-The accused named **Duong Samnang** (absent)
-Attorney **Seng Reach**, defending the rights of the accused named **Chea Chan** (present)
-Attorney **Hong Sambath**, defending the rights of the accused named **Chea Chan** (present)
-Attorney **Seang Rady**, defending the rights of the accused named **Duong Samnang** (present)
-Chair of the Hearing Council reading the report of the briefs of the course [of the matter]

**-The Clerk Court read the answers of the civil petitioner.**

-**The accused** named **Chea Chan**, responded: He would like to reject his answer given before the judicial police officer because at the time he only saw the action of **Duong Samnang** performing a mechanic job not an action of theft. It was merely an action of fixing the motor. He is of a role as the mechanic supervisor, someone who inspects the action of the mechanic, and who has 7 team members; **Duong Samnang** was not his team member. Changing of motor was within the premises of the factory inside the building, and he saw **Duong Samnang** took apart the motor during working hours at the station where the mechanic works. **Duong Samnang**'s action, in his mind, was an action of a mechanic on duty only. Someone filed a complaint against him on the matter since 2022, with **Or Sam Un** being the one who made accusations against him. It was not until 2024 that he was arrested by the competent authorities at the workplace itself without any court order while the competent authorities told him to hop on the car first and [he would] find out.

-**Mandatory prosecution-general made the conclusion**: The accused responded like he did before; there wasn't any changes. The mandatory prosecution-general requests the council to consider the answer of the witness named **Or Sam Un** because [he] seemed to speak in an imaginative way without any basis and clear evidence; the arrest and imprisonment of any individual should be accompanied by proper evidence. The council is requested to also consider the responses of the civil

[*stamp*]

petitioner. On the other hand, was there any power of attorney from the representative for the filing of the complaint? Even though the complaint did not demand any compensation, but his complaint affected the other person, and in the response of the petitioner, there was not any clear evidence because the petitioner only learnt from the response of **Or Sam Un**, and the filing of this complaint is according to the response of **Or Sam Un** only. The petitioner clarified of the lost items such as 382 valves of motor, 50 USD per piece, some electric wire, air machine at 2 locations while the matter of fact was described as, **"committed the act of theft of cooper of the footwear factory**"; what sort of cooper? In the complaint, a number of lost items were described. Instead, in the matter of fact, it was described as cooper being loss; the council is requested to consider this aspect. It appears that there was not any evidence outside the words of **Or Sam Un**. The petitioner, on the other hand, had no evidence of any kinds at all, and it was the same for the accused named **Duong Samnang**, i.e. there was not any evidence for the accusation. Therefore, the mandatory prosecutor-general finds that there was not any evidence indicating that the accused named **Chea Chan** and **Duong Samnang** had committed an offense. Based on the above reasons and evidence of the above stated, the mandatory prosecutor-general requests the council to kindly consider [and] rule.

-**Seng Reach**, attorney defending the rights of the accused, named **Chea Chan**, made the conclusion: He agrees completely with the conclusion by the mandatory prosecutor-general, and requests the council to reject judgment No. **770 (ឧ), dated 20 June 2024**, of the Kompong Speu Provincial Court of First Instance, and requests the council to release his client, named **Chea Chan**, to freedom because his client has served the sentence for **6 months so** far [and is] due to end on **16 August 2024**.

-**Hong Sambath**, attorney defending the rights of the accused, named **Chea Chan**, made the conclusion: He agrees with what is stated by his colleague.

-**Seang Rady**, attorney defending the rights of the accused, named **Duong Samnang**, made the conclusion: Regarding the accusation against his client, it is also raised by the mandatory prosecution-general that there is not any evidence to affirm that his client has committed theft. As for elements of crime, there did not seem to be enough element to make the accusation against his client, and the ruling made by the Kompong Speu Provincial Court of First Instance seems to be unjust for his client. Therefore, the council is requested to kindly examine, consider [and] rule over the decision of the Kompong Speu Provincial Court of First Instance, at **Item 1.1 and Item 2** because the above petitioner did not have enough evidence [and] based only on the responses given by the witness, named **Or Sam Un**. Based on **Article 38 of the Constitution**, the accused shall enjoy the benefits of doubts. Therefore, the council is requested to drop the accusation and rule to cease the order to arrest his client.

-**The accused**, named **Chea Chan**, made the request: The court is requested to kindly release him to freedom and to reject the judgment of the Kompong Speu Provincial Court of First Instance.

-Having listened to the report reading,
-Having listened to the responses of the accused,
-Having listened to the reading of responses of the civil petitioner,
-Having listened to the conclusion by the mandatory prosecutor-general,
-Having listened to the conclusion of the attorneys defending the rights of the accused,
-Having listened to the final request made by the accused,
-Having examined the evidence and relevant documents,

[*stamp*]

-Having examined and duly discussed in accordance with the law,

**The Criminal Chamber of the Court of Appeal**

**Finds**

1-Appeal No.: **109, dated 02 July 2024**, of **Horm Sunrith** and **Seng Reach,** attorneys defending the rights of the accused, named **Chea Chan**, and appeal No. **117, dated 17 July 2024**, of the accused, named **Duong Samnang**, appealing the criminal judgement No. **770 (ខ), dated 20 June 2024**, of the Kompong Speu Provincial Court of First Instance, on **item of the entire ruling**, is made in accordance with the legal timeframe; the Court of Appeal accepts adjudicating as its competence, based on **Article 43, of the Law on the Organization of Judicial Bodies**, **and Article 373, of the Code on Criminal Procedures**.

2-**The accused**, named **Chea Chan**, responded: He would like to reject his answer given before the judicial police officer because at the time he only saw the action of **Duong Samnang** performing a mechanic job not an action of theft. It was merely an action of fixing the motor. He is of a role as the mechanic supervisor, someone who inspects the action of the mechanic, and who has 7 team members; **Duong Samnang** was not his team member. Changing of motor was within the premises of the factory inside the building, and he saw **Duong Samnang** took apart the motor during working hours at the station where the mechanic works. **Duong Samnang**'s action, in his mind, was an action of a mechanic on duty only. Someone filed a complaint against him on the matter since 2022, with **Or Sam Un** being the one who made accusations against him. It was not until 2024 that he was arrested by the competent authorities at the workplace itself without any court order while the competent authorities told him to hop on the car first and [he would] find out.

The response of the said accused is in compliance with the compliant and responses of the civil petitioner, named **Banh Siem Ann**, stating that the lost items were **382 valves of motor**, **50 USD per piece**, some electric wire, **2** air machine; there was not any loss of the motor or motor cooper. Therefore, the rejection by the above accused is supported by evidence.

3-**Based on the reading of the responses of the civil petitioner**, named **Banh Siem Ann**, it was answered: He has been a representative of the Wing Star Shoe footwear factory for about **20 years**. The Wing Star Shoe footwear factory had previously lost a number of items without knowing who stole them. Sometimes, the factory would catch the theft, but with petty theft, they are then dismissed from their job. It was not until 12 February 2024 at 15:58 that the B8 security saw **Or Sam Un** steal 01 valve of motor [and] hid inside his shirt. The security asked that mechanic for a material checkout card, and **Or Sam Un** responded he did not have such a thing, and motor valve was broken, so he took it to his own motorbike. The security barred the person from leaving the factory because it was working hours, and **Or Sam Un** returned to the workplace and threw the motor valve away before the security allowed **Or Sam Un** to leave work as usual. At 4:00, the security reported to the chief of security that **Or Sam Un** stole **01** valve of motor [and] hid it inside his shirt. The section chief then reported to the general manager that the security guard caught a mechanic stealing **01** valve of motor, preparing to bring it outside. However, the security guard did not ask much because it was time for the worker to leave work. Next day, the factory checked the security camera and saw that **Or Sam Un** was indeed stealing the motor valves. Then, [they] called for an inquiry, [and] **Or Sam Un** confessed before the factory filed a complaint to the administrative police station of Moha Russey. On 14 February 2024 at

[*stamp*]

15 o'clock in the afternoon, the competent authority arrived at the factory and found **Chea Chan** and **Duong Samnang** involve in the case of theft of items in the factory; he then filed additional complaint on top of **Or Sam Un** [for] **Chea Chan** and **Duong Samnang**. He wishes to add that previously, **Or Sam Un**, **Chea Chan** and **Duong Samnang** did steal materials in the factory, but there was not any clear evidence, which is why the factory did not file a complaint. The items lost were **382** valves of motor, **50 (fifty) USD** per piece, some electric wire, air machines at **02 places**. He requests the court to punish the accused in accordance with the law.

Based on the response of the petitioner, it is found that the petitioner filed a complaint against **Chea Chan** and **Duong Samnang** based solely on the responses of **Or Sam Un** without any other evidence as the basis.

**4**-Based on the reading of the answer of the witness, named **Or Sam Un**, it was stated that in 2022, he and **Cheang Chek** saw **Duong Samnang** and **Chea Chan** steal other people's items. He then walked away. He did not know how much they stole. They were cutting the motor open for cooper that was on the inside, one motor of which had about one kilogram of cooper, to be sold to the waste pickers.

The response of the witness in stating that the two accused secretly cut open [the motor] for the motor's cooper is only a speculation of this witness because based on the answer of the accused named **Chea Chan**, that he saw **Duong Samnang** took apart the motor during working hour and [it was done] at a location that the mechanic was working, which was a normal activity of a mechanic only, and based on the above responses of the petitioner indicating the lost items, motor or motor cooper was not listed.

**5**-Based on the above reasons, there is not any matter of fact of motor theft committed by the accused named **Chea Chan** and **Duong Samnang** that occurred in 2022 at the location of the **Wing Star Shoe** footwear factory, located in Ang Sokunthea village, Moha Russey commune, Korng Pisey district, Kompong Speu province.

**6-The mandatory prosecutor-general made the conclusion**: The accused responded like he did before; there wasn't any changes. The mandatory prosecution-general requests the council to consider the answer of the witness named **Or Sam Un** because [he] seemed to speak in an imaginative way without a basis and clear evidence; the arrest and imprisonment of any individual should be accompanied by proper evidence. The council is requested to consider the responses of the civil petitioner. On the other hand, was there any power of attorney from the representative for the filing of the complaint? Even though the complaint did not demand any compensation, but his complaint affected the other person, and in the response of the petitioner, there was not any clear evidence because the petitioner only learnt from the response of **Or Sam Un** only, and the filing of this complaint is according to the response of **Or Sam Un**. The petitioner clarified of the lost items such as 382 valves of motor, 50 USD per piece, some electric wire, air machine at 2 locations whereas the matter of fact was described as, **"committed the act of theft of cooper of the footwear factory"**; what sort of cooper? In the complaint, a number of lost items were described. Instead, in the matter of fact, it was described as cooper being loss; the council is requested to consider this aspect. It appears that there was not any evidence outside the words of **Or Sam Un**. The petitioner, on the other hand, had no evidence of any kinds at all, and it was the same for the accused named **Duong Samnang**, i.e. there was not any evidence for the accusation. Therefore, the mandatory prosecutor-general finds that

[*stamp*]

there was not any evidence indicating that the accused named **Chea Chan** and **Duong Samnang** had committed an offense. Based on the above reasons and evidence of the above stated, the mandatory prosecutor-general requests the council to kindly consider [and] rule.

**This conclusion is of proper ground in accordance with the law.**

**7- Seng Reach**, attorney defending the rights of the accused, named **Chea Chan**, made the conclusion: He agrees completely with the conclusion of the mandatory prosecution-general and requests the council to reject the judgment No. **770 (ឧ), dated 20 June 2024**, of the Kompong Speu Provincial Court of First Instance, and request the council to kindly release his client, named **Chea Chan**, to freedom because his client has implemented the punishment for **6 months** so far to be concluded on **18 August 2024**.

**This conclusion is of proper ground in accordance with the law.**

**8-Seang Rady**, attorney defending the rights of the accused, named **Duong Samnang**, made the conclusion: Regarding the accusation against his client, it is also raised by the prosecution-general that there is not any evidence to affirm that his client has committed theft. As for elements that constitute crime, there did not seem to be enough element to accuse his client, and the ruling made by the Kompong Speu Provincial Court of First Instance seems to be unjust for his client. Therefore, the council is requested to kindly examine, consider [and] rule over the decision of the Kompong Speu Provincial Court of First Instance, at **Item 1.1** and **Item 2** because the petitioner did not have enough evidence [and] based only on the responses given by the witness, named **Or Sam Un**, only. Based on **Article 38 of the Constitution**, the accused shall enjoy the benefits of the doubts. Therefore, the council is requested to drop the accusation and rule to cease the order to arrest his client.

**This conclusion is of proper ground in accordance with the law.**

**9**-There is no guilt pertaining the accused, named **Chea Chan**, for **conspiracy to commit theft**, committed at the location of Wing Star Shoe footwear factory, located in Ang Sokunthea village, Moha Russey commune, Korng Pisey district, Kompong Speu province, during 2022, a criminal offense stipulated and punishable in accordance with the provisions of **Articles 29, 353** and **356 of the Criminal Code.**

**10**-There is no guilt pertaining the accused, named **Duong Samnang**, for **theft**, committed at the location of Wing Star Shoe footwear factory, located in Ang Sokunthea village, Moha Ruseey commune, Korng Pisey district, Kompong Speu province, during 2022, a criminal offense stipulated and punishable in accordance with the provisions of **Articles 353** and **356 of the Criminal Code**.

**11**-Criminal judgement No. **770 (ឧ), dated 20 June 2024**, of the Kompong Speu Provincial Court of First Instance, sentencing the accused, named **Chea Chan**, and the accused, named **Duong Samnang**, is incorrect. The criminal chamber should reject it, **in accordance with Article 405 of the Code on Criminal Procedures**.

**12**-There is no evidence to affirm that the accused, named **Duong Samnang**, received a summons to appear at the hearing; therefore, this ruling shall be deemed a default ruling, with appeal being authorized in accordance with the legal timeframe.

**Therefore,**

[*stamp*]

**It is adjudicated**

**1-Accept** the appeal No.: **109, dated 02 July 2024**, of **Horm Sunrith** and **Seng Reach**, attorneys defending the rights of the accused, named **Chea Chan**.

**2-Accept** the appeal No. **117, dated 17 July 2024**, of the accused, named **Duong Samnang**.

**3-Reject** the criminal judgement No.: **770 (ឧ), dated 20 June 2024**, of the Kompong Speu Provincial Court of First Instance.

**4-Release the accused, named Chea Chan, from the charge** for **conspiracy to commit theft**, committed at the location of Wing Star Shoe footwear factory, located in Ang Sokunthea village, Moha Russey commune, Korng Pisey district, Kompong Speu province, during 2022, a criminal offense stipulated and punishable in accordance with the provisions of **Articles 29, 353 and 356 of the Criminal Code.**

**5-Release the accused, named Duong Samnang, from the charge** for **theft**, committed at the location of Wing Star Shoe footwear factory, located in Ang Sokunthea village, Moha Ruseey commune, Korng Pisey district, Kompong Speu province, during 2022, a criminal case stipulated and punishable in accordance with the provisions of Articles **353** and **356** of the Criminal Code.

**6**-Cease the arrest of the accused, named **Duong Samnang**.

-The ruling herewith was heard in public on **19 August 2024** before the accused, named **Chea Chan**, [and] in default of **Duong Samnang**, and was publicly pronounced **on 22 August 2024**.

-Objection and appeal are authorized within the legal timeframe.

| **Clerk of the Court** | **Advisory Judge** | **Chair of the Hearing Council** |
|---|---|---|
| Signature: **Uch Kenbo** | Signature: **Keo Mony, You Bunna** | Signature: **Duch Soksarin** |

**"Duly copied from the original"**
**Thursday, the 3rd day of the wanning moon of the ninth lunar month, in the Year of the Dragon, B.E. 2568**
**Phnom Penh Court of Appeal, 22 August 2024**
**Clerk of the Court**
[*signature and stamp*]

**UCH KENBO**

**Seen**
**Chair of the Hearing Council**
[*signature and stamp*]

**DUCH SOKSARIN**

[*stamp*]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងសភាព្រហ្មទណ្ឌ

លេខៈ ១២៥៥

ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៤

សាលដីកា

លេខៈ ១៣០ "ក្រIV ឌ.រ"

ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤

# គាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

សភាព្រហ្មទណ្ឌបង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។

បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ភ្នំពេញ នាថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤ ដោយមាន ៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក **ឌុច សុខសារិន** ជាប្រធានក្រុមប្រឹក្សា

ឯកឧត្តម **ឃួ ម៉ិនណា** ជាចៅក្រមប្រឹក្សា

លោក **កែវ មុនី** ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

ឯកឧត្តម **អ៊ឹម សុផាន** អគ្គព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក **អ៊ុច កែនបូ**

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍លេខៈ ១០៩ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៤ របស់មេធាវីហម ស៊ុនរិទ្ធិ និងមេធាវីសេង រាជ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ជា ចាន់ និងបណ្តឹងឧទ្ធរណ៍លេខៈ ១១៧ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤របស់ជនជាប់ចោទឈ្មោះ ដួង សំណាង សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ៧៧០ (ឌ) ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ដែលមាន៖

១-ជនជាប់ចោទឈ្មោះ ជា ចាន់ ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរជាងម៉ាស៊ីនរោងចក្រ ទីកន្លែងកំណើតនៅភូមិនរាយណ៍ ឃុំពោធិ៍អង្គ្រង ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូមិនរាយណ៍ ឃុំពោធិ៍អង្គ្រង ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ អ៊ិន សារ៉េត "ស្លាប់" ម្តាយឈ្មោះ ឈិត លី "រស់" ប្រពន្ធឈ្មោះ ផែ ចាន់រ៉ា មានកូន០៣នាក់ ជានីតិជន ទោសពីមុនគ្មាន។ (ក្នុងឃុំ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខៈ ១៨៨ "ឃ" ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៤ នៅពន្ធនាគារខេត្តកំពង់ស្ពឺ។

ជាប់ចោទពីបទៈ **សមគំនិតក្នុងអំពើលួច** ប្រព្រឹត្តនៅចំណុចរោងចក្រផលិតស្បែកជើង វីង ស្តារស៍ ស្ថិតនៅភូមិអង្គសុគន្ធា ឃុំមហាឫស្សី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែង

និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩, មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

**-មេធាវី សេង រាជ និងមេធាវី ហុង សម្បត្តិ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ជា ចាន់**

**២-ជនជាប់ចោទឈ្មោះ ដួង សំណាង** ភេទប្រុស កើតឆ្នាំ១៩៨៧ ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិនរាយណ៍ ឃុំពោធិ៍អង្រ្គង ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូមិនរាយណ៍ ឃុំពោធិ៍អង្រ្គង ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ **ស៊ឹម ទឹម** “រស់” ម្តាយឈ្មោះ **ស៊ឹម សារីម** “រស់” ប្រពន្ធឈ្មោះ ដាន់ ស្រីមុំ មានកូន០២នាក់ ជានីតិជន ទោសពីមុនគ្មាន។ (គេចខ្លួន)

-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ: ៣១៣ (ខ) ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ របស់ចៅក្រមជំនុំជម្រះនៃសាលាដំបូងខេត្តកំពង់ស្ពឺ។

ជាប់ចោទពីបទ: លួច ប្រព្រឹត្តនៅចំណុចរោងចក្រផលិតស្បែកជើង វីង ស្តារស៊្វ ស្ថិតនៅភូមិអង្គសុគន្ធា ឃុំមហាឫស្សី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

**-មេធាវី ស៊ាង វ៉ាឌី ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ដួង សំណាង**

**-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ បាញ់ សៀមអាន** ភេទប្រុស កើតឆ្នាំ១៩៥៤ អាសយដ្ឋានបច្ចុប្បន្នស្នាក់នៅភូមិ២ សង្កាត់៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ តំណាងឱ្យក្រុមហ៊ុន វីង ស្តារស៊្វ។

## <u>អំពីអង្គហេតុ</u>

កាលពីអំឡុងឆ្នាំ២០២២ នៅចំណុចរោងចក្រផលិតស្បែកជើង វីង ស្តារស៊្វ ស្ថិតនៅភូមិអង្គសុគន្ធ ឃុំមហាឫស្សី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ មានករណីលួច **និងសមគំនិតក្នុងអំពើលួច** មួយបានកើតឡើង ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ **ជា ចាន់** ភេទប្រុស អាយុ៤០ឆ្នាំ និងឈ្មោះ **ដួង សំណាង** ភេទប្រុស អាយុ៣៧ឆ្នាំ។ នៅពេលកើតហេតុ ឈ្មោះ **ដួង សំណាង** ធ្វើសកម្មភាពលួចយកស្តាន់របស់រោងចក្រស្បែកជើង វីង ស្តារស៊្វ ដោយមានឈ្មោះ **ជា ចាន់** ជាអ្នកចាំមើលផ្លូវ។ ក្រោយកើតហេតុជនរងគ្រោះឈ្មោះ **បាញ់ សៀមអាន** ភេទប្រុស អាយុ៧០ឆ្នាំ បានដាក់ពាក្យបណ្តឹងទៅស្នងការនគរបាលខេត្តកំពង់ស្ពឺ រួចសមត្ថកិច្ចបានឃាត់ខ្លួនជនជាប់ចោទខាងលើ និងកសាងសំណុំរឿងបញ្ជូនមកកាន់អយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

**-បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ: ៧៧០ (ខ) ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

**១/.ផ្តន្ទាទោស៖**

**១.១-ឈ្មោះ ដួង សំណាង** ភេទប្រុស កើតឆ្នាំ១៩៨៧ ដាក់ពន្ធនាគារកំណត់រយៈពេល ១(មួយ)ឆ្នាំ ពីបទ លួច ប្រព្រឹត្តនៅចំណុចរោងចក្រផលិតស្បែកជើង វីង ស្តារស៊្វ ស្ថិតនៅភូមិអង្គសុគន្ធា ឃុំមហាឫស្សី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣

និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

១.២-ឈ្មោះ ជា ចាន់ ភេទប្រុស អាយុ៤០ឆ្នាំ ដែលមានអត្តសញ្ញាណខាងលើ ដាក់ពន្ធនាគារកំណត់រយៈពេល ១ (មួយ) ឆ្នាំ តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគាររយៈពេល ៦ (ប្រាំមួយ) ខែ ទោសនៅសល់ត្រូវព្យួរតាមបទបញ្ញត្តិស្តីពីការព្យួរទោសធម្មតា នៃក្រមព្រហ្មទណ្ឌ ពីបទ សមគំនិតក្នុងអំពើលួច ប្រព្រឹត្តនៅចំណុចរោងចក្រផលិតស្បែកជើង វីង ស្តារស៊ូ ស្ថិតនៅភូមិអង្គសុគន្ធា ឃុំមហាឫស្សី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

២-បញ្ឈប់ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ:៩៣ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤ ចេញដោយចៅក្រមស៊ើបសួរ និងបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ ដួង សំណាង ភេទប្រុស កើតឆ្នាំ១៩៨៧ ជាថ្មីម្តងទៀត។

សាលក្រមនេះ ជំនុំជម្រះនៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទឈ្មោះ ជា ចាន់ កំបាំងមុខជនជាប់ចោទឈ្មោះ ដួង សំណាង កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី២០ ខែមិថុនាឆ្នាំ២០២៤ ទុកសិទ្ធិប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ: ១០៩ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៤ របស់មេធាវី ហម ស៊ុនរិទ្ធិ និងមេធាវី សេង រាជ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ជា ចាន់ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: ៧៧០ (ឌ) ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ: ១១៧ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤ របស់ជនជាប់ចោទឈ្មោះ ដួង សំណាង សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: ៧៧០ (ឌ) ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ របាយការណ៍សំណុំរឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍នៃសាលាឧទ្ធរណ៍។

-បានឃើញ សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។

**<u>នាពេលសវនាការៈ</u>**

-ជនជាប់ចោទឈ្មោះ ជា ចាន់ (វត្តមាន)

-ជនជាប់ចោទឈ្មោះ ដួង សំណាង (អវត្តមាន)

-មេធាវី សេង រាជ ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ជា ចាន់ (វត្តមាន)

-មេធាវី ហុង សម្បត្តិ ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ជា ចាន់ (វត្តមាន)

-មេធាវី ស៊ាង រ៉ាឌី ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ដួង សំណាង (វត្តមាន)

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានរបាយការណ៍សង្ខេបរឿង

-ក្រឡាបញ្ជីបានអានអំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

-ជនជាប់ចោទឈ្មោះ ជា ចាន់ បានឆ្លើយថា៖ ខ្លួនសូមបដិសេធចម្លើយដែលខ្លួនបានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ព្រោះពេលនោះខ្លួនបានឃើញសកម្មភាពរបស់ឈ្មោះ ដួង សំណាង កំពុងធ្វើការងារជាង មិនមែនជាសកម្មភាពលួចនោះទេ គឺគ្រាន់តែជាសកម្មភាពធ្វើម៉ូទ័រតែប៉ុណ្ណោះ។ ខ្លួនមានតួនាទីជាប្រធានផ្នែកជាង ជាអ្នកត្រួតពិនិត្យលើសកម្មភាពជាង និងមានកូនក្រុមចំនួន៧នាក់ ហើយឈ្មោះ ដួង សំណាង មិនមែនជាកូនក្រុមរបស់ខ្លួនទេ។ ការផ្លាស់ប្ដូរម៉ូទ័រ គឺនៅក្នុងបរិវេណរោងចក្រស្ថិតក្នុងអគារ ហើយខ្លួនឃើញឈ្មោះ ដួង សំណាង ធ្វើការដោះម៉ូទ័រនៅក្នុងម៉ោងការងារ និងស្ថិតនៅទីតាំងដែលជាងធ្វើការ ហើយសកម្មភាពឈ្មោះ ដួង សំណាង ខ្លួនគិតថាជាសកម្មភាពរបស់ជាងកំពុងធ្វើការប៉ុណ្ណោះ។ រឿងនេះមានគេប្ដឹងខ្លួនតាំងពីឆ្នាំ២០២២ ដែលមានឈ្មោះ ឱ សំអុន ជាអ្នកឆ្លើយចោទប្រកាន់មកលើខ្លួន លុះដល់ឆ្នាំ២០២៤ ខ្លួនត្រូវបានសមត្ថកិច្ចមកចាប់ខ្លួននៅកន្លែងការងារតែម្ដងដោយគ្មានដីកាពីតុលាការនោះទេ ហើយសមត្ថកិច្ចបានប្រាប់ថាឱ្យខ្លួនឡើងឡានសិនទៅដឹងហើយ។

-តំណាងមហាអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖ ជនជាប់ចោទបានឆ្លើយចម្លើយដូចពីមុនមក មិនមានអ្វីប្រែប្រួលនោះទេ តំណាងមហាអយ្យការស្នើក្រុមប្រឹក្សាពិចារណាលើចម្លើយរបស់សាក្សីឈ្មោះ ឱ សំអុន ព្រោះហាក់និយាយបែបស្រមើស្រមៃគ្មានមូលដ្ឋាន និងភស្តុតាងច្បាស់លាស់ ហើយការចាប់ខ្លួន និងការដាក់ពន្ធនាគារលើជនណាមួយ គួរតែមានភស្តុតាងឱ្យបានត្រឹមត្រូវ ហើយក៏ស្នើក្រុមប្រឹក្សាពិចារណាលើចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ។ មួយវិញទៀត តើមានលិខិតផ្ទេរសិទ្ធិអំពីតំណាងក្នុងការឱ្យប្ដឹងដែរឬទេ? ទោះបីជាការប្ដឹងនោះមិនបានទាមទារសំណងក៏ដោយ ប៉ុន្តែការប្ដឹងរបស់គាត់គឺធ្វើឱ្យគេរងគ្រោះ ហើយក្នុងចម្លើយរបស់ដើមបណ្ដឹងមិនមានភស្តុតាងច្បាស់ ព្រោះដើមបណ្ដឹងដឹងដោយសារចម្លើយរបស់ឈ្មោះ ឱ សំអុន ប៉ុណ្ណោះ ហើយការដាក់ពាក្យបណ្ដឹងនេះ គឺដាក់តាមចម្លើយរបស់ឈ្មោះ ឱ សំអុន ហើយដើមបណ្ដឹងបានបញ្ជាក់ពីការបាត់សម្ភារ៖ មានដូចជាក្បាលប៊ិចម៉ូទ័រ ចំនួន៣៨២គ្រាប់ មានតម្លៃក្នុងមួយក្បាល៥០ដុល្លារ, ខ្សែភ្លើងមួយចំនួន, ម៉ាស៊ីនខ្យល់ ចំនួន២កន្លែង រីឯអង្គហេតុវិញ គឺបានរៀបរាប់ថា "ធ្វើសកម្មភាពលួចស្ពាន់របស់រោងចក្រស្បែកជើង" តើជាស្ពាន់អ្វី? ក្នុងពាក្យបណ្ដឹងសរសេរបញ្ជាក់អំពីការបាត់សម្ភារៈផ្សេងៗ តែពេលនៅក្នុងអង្គហេតុបែរជាសរសេរអំពីការបាត់ស្ពាន់ទៅវិញ ត្រង់ចំណុចនេះសូមក្រុមប្រឹក្សាពិចារណា។ ឃើញថា មិនមានភស្តុតាងណាមួយក្រៅពីសម្ដីរបស់ឈ្មោះ ឱ សំអុន នោះទេ ចំណែកឯដើមបណ្ដឹងមិនមានភស្តុតាងអ្វីទាល់តែសោះ ហើយចំពោះជនជាប់ចោទឈ្មោះ ដួង សំណាង ក៏ដូចគ្នាដែរ គឺមិនឃើញមានភស្តុតាងណាមួយឡើយក្នុងការចោទប្រកាន់។ ដូចនេះតំណាងមហាអយ្យការយល់ឃើញថាពុំទាន់ឃើញមានភស្តុតាងណាមួយដែលបង្ហាញថាជនជាប់ចោទឈ្មោះ ជា ចាន់ និងឈ្មោះ ដួង សំណាង បានប្រព្រឹត្តបទល្មើសនោះឡើយ ដោយសំអាងលើហេតុផល និងភស្តុតាងនៃការលើកឡើងខាងលើ តំណាងមហាអយ្យការស្នើក្រុមប្រឹក្សាពិនិត្យពិចារណាសម្រេច។

-មេធាវី សេង រាជ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ជា ចាន់ បានធ្វើសេចក្ដីសន្និដ្ឋានថា៖

ខ្លួនសូមឯកភាពទាំងស្រុងលើការសន្និដ្ឋានរបស់តំណាងមហាអយ្យការ និងសូមសំណូមពរដល់ក្រុមប្រឹក្សាមេត្តាបដិសេធចោលនូវសាលក្រមលេខ: ៧៧០ (ឧ) ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកំពង់ស្ពឺ និងសូមស្នើសុំក្រុមប្រឹក្សាមេត្តាដោះលែងកូនក្តីខ្លួនឈ្មោះ **ជា ចាន់** ឱ្យមានសេរីភាពឡើងវិញ ព្រោះកូនក្តីខ្លួនបានអនុវត្តទោសដល់សព្វថ្ងៃបាន **៦ខែ** មកហើយ នឹងត្រូវចប់នៅថ្ងៃទី១៨ **ខែសីហា ឆ្នាំ២០២៤** នេះផងដែរ។

-មេធាវី **ហុង សម្បត្តិ** ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ **ជា ចាន់** បានធ្វើសេចក្តីសន្និដ្ឋានថា: ខ្លួនសូមឯកភាពតាមការលើកឡើងរបស់សហភាគា។

-មេធាវី **ស៊ាង វ៉ាឌី** ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ **ដួង សំណាង** បានធ្វើសេចក្តីសន្និដ្ឋានថា: ចំពោះការចោទប្រកាន់មកលើកូនក្តីខ្លួន គឺតំណាងមហាអយ្យការក៏បានលើកឡើងដែរថា មិនមានភស្តុតាងណាមួយបញ្ជាក់ថាកូនក្តីខ្លួនបានប្រព្រឹត្តអំពើលួចនោះឡើយ ចំពោះធាតុផ្សំនៃបទល្មើស ក៏មិនមានធាតុផ្សំគ្រប់គ្រាន់ក្នុងការចោទប្រកាន់កូនក្តីខ្លួនដែរ ហើយការសម្រេចរបស់តុលាការខេត្តកំពង់ស្ពឺ ហាក់មានភាពអយុត្តិធម៌មកលើកូនក្តីខ្លួន ដូច្នេះ សូមស្នើសុំក្រុមប្រឹក្សាមេត្តាពិនិត្យពិចារណាសម្រេចលើសេចក្តីសម្រេចរបស់តុលាការសាលាដំបូងខេត្តកំពង់ស្ពឺ **ត្រង់ចំណុចទី១.១** និងចំណុចទី២ ព្រោះថាខាងដើមបណ្តឹងមិនមានភស្តុតាងគ្រប់គ្រាន់ឡើយ ដោយផ្អែកតែលើចម្លើយរបស់សាក្សីឈ្មោះ **ឱ សំអុន** តែប៉ុណ្ណោះ យោងតាមមាត្រា ៣៨ **នៃរដ្ឋធម្មនុញ្ញ** វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ដូច្នេះ សូមក្រុមប្រឹក្សាមេត្តាលើកលែងចោទប្រកាន់ និងសម្រេចបញ្ឈប់ដីកាចាប់ខ្លួនមកលើកូនក្តីខ្លួន។

-**ជនជាប់ចោទ**ឈ្មោះ **ជា ចាន់** បានសំណូមពរថា: សូមតុលាការមេត្តាដោះលែងខ្លួន ឱ្យមានសេរីភាព និងសូមបដិសេធចោលនូវសាលក្រមសាលាដំបូងខេត្តកំពង់ស្ពឺ។

-ក្រោយពីបានស្តាប់អំណានរបាយការណ៍

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីពិនិត្យភស្តុតាង និងឯកសារពាក់ព័ន្ធ

-ក្រោយពីបានពិនិត្យ និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍**

**យល់ឃើញថា:**

១-បណ្តឹងឧទ្ធរណ៍លេខ: ១០៩ ចុះថ្ងៃទី០២ **ខែកក្កដា ឆ្នាំ២០២៤** របស់មេធាវី **ហ៊ាម ស៊ុនរិទ្ធិ** និងមេធាវី

សេង រាជ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ជា ចាន់ និងបណ្តឹងឧទ្ធរណ៍លេខ: ១១៧ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤ របស់ជនជាប់ចោទឈ្មោះ ដួង សំណាង សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: ៧៧០ (ខ) ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះជាសមត្ថកិច្ចយោងតាមមាត្រា៤៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា៣៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**២-ជនជាប់ចោទឈ្មោះ ជា ចាន់** បានឆ្លើយថា: ខ្លួនសូមបដិសេធចម្លើយដែលខ្លួនបានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ព្រោះពេលនោះខ្លួនបានឃើញសកម្មភាពរបស់ឈ្មោះដួង **សំណាង** កំពុងធ្វើការងារជាង មិនមែនជាសកម្មភាពលួចនោះទេ គឺគ្រាន់តែជាសកម្មភាពធ្វើម៉ូទ័រតែប៉ុណ្ណោះ។ ខ្លួនមានតួនាទីជាប្រធានផ្នែកជាង ជាអ្នកត្រួតពិនិត្យលើសកម្មភាពជាង និងមានកូនក្រុមចំនួន៧នាក់ ហើយឈ្មោះ **ដួង សំណាង** មិនមែនជាកូនក្រុមរបស់ខ្លួនទេ។ ការផ្លាស់ប្តូរម៉ូទ័រ គឺនៅក្នុងបរិវេណរោងចក្រស្ថិតក្នុងអគារ ហើយខ្លួនឃើញឈ្មោះ **ដួង សំណាង** ធ្វើការដោះម៉ូទ័រនៅក្នុងម៉ោងការងារ និងស្ថិតនៅទីតាំងដែលជាងធ្វើការ ហើយសកម្មភាពឈ្មោះ **ដួង សំណាង** ខ្លួនគិតថាជាសកម្មភាពរបស់ជាងកំពុងធ្វើការប៉ុណ្ណោះ។ រឿងនេះមានគេប្តឹងខ្លួនតាំងពីឆ្នាំ២០២២ ដែលមានឈ្មោះ **ឱ សំអុន** ជាអ្នកឆ្លើយចោទប្រកាន់មកលើខ្លួន លុះឆ្នាំ២០២៤ ខ្លួនត្រូវបានសមត្ថកិច្ចមកចាប់ខ្លួននៅកន្លែងការងារតែម្តង ដោយគ្មានដីកាពីតុលាការនោះទេ ហើយសមត្ថកិច្ចបានប្រាប់ថាឱ្យខ្លួនឡើងឡានសិនទៅដឹងហើយ។

ចម្លើយរបស់ជនជាប់ចោទនេះ ស្របគ្នានឹងពាក្យបណ្តឹង និងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **បាញ់ សៀមអាន** ដែលបានបញ្ជាក់ថា សម្ភារៈដែលបាត់បង់មាន ក្បាលប៊ិចម៉ូទ័រចំនួន**៣៨២គ្រាប់** ក្នុងមួយគ្រាប់**តម្លៃ៥០ដុល្លារអាមេរិក,** ខ្សែភ្លើងមួយចំនួន និងម៉ាស៊ីនខ្យល់ចំនួន**២** គឺពុំមានបាត់បង់ម៉ូទ័រ ឬស្តាន់ម៉ូទ័រឡើយ ដូចនេះ ចម្លើយបដិសេធរបស់ជនជាប់ចោទខាងលើត្រូវបានគាំទ្រដោយភស្តុតាង។

**៣-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះបាញ់ សៀមអាន** បានឆ្លើយថា: ខ្លួនជាតំណាងឱ្យរោងចក្រផលិតស្បែកជើង វីងស្តាស៊្វ រយៈពេលប្រហែល **២០ឆ្នាំ** មកហើយ។ កន្លងមករោងចក្រផលិតស្បែកជើង វីងស្តាស៊្វ បានបាត់សម្ភារៈមួយចំនួនដោយមិនដឹងថាអ្នកណាជាអ្នកលួច និងពេលខ្លះខាងរោងចក្រចាប់អ្នកលួចបានដែរ ប៉ុន្តែលួចតិចតួចក៏បញ្ឈប់ពីការងារ។ លុះដល់ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង ១៥ និង ៥៨នាទី ខាងសន្តិសុខប៉េប្រាំបី ឃើញឈ្មោះ **ឱ សំអុន** លួចក្បាលប៊ិច ម៉ូទ័រ ចំនួន០១ លាក់ទុកក្នុងអាវ សន្តិសុខក៏សួរទៅខាងជាងផ្នែកម៉ាស៊ីននោះរកប័ណ្ណយកសម្ភារៈចេញក្រៅ ហើយឈ្មោះ **ឱ សំអុន** ឆ្លើយថា អត់មានទេ ហើយថាក្បាលប៊ិចម៉ូទ័រនេះខូច គាត់យកទៅដាក់ម៉ូតូរបស់គាត់។ សន្តិសុខមិនឱ្យឈ្មោះនេះចេញទៅក្រៅរោងចក្រទេ ព្រោះក្នុងកំឡុងពេលកំពុងធ្វើការ ហើយឈ្មោះ **ឱ សំអុន** ក៏ត្រឡប់ទៅកន្លែងធ្វើការវិញ និងបោះក្បាលប៊ិចម៉ូទ័រនោះចោល ទើបសន្តិសុខឱ្យឈ្មោះ **ឱ សំអុន** ចេញពីធ្វើការធម្មតា។ លុះម៉ោង ០៤ និង០០នាទី សន្តិសុខក៏រាយការណ៍ជូនប្រធានផ្នែកសន្តិសុខថាឈ្មោះ**ឱ សំអុន** បានលួចក្បាលប៊ិចម៉ូទ័រ ចំនួន០១ លាក់ទុកក្នុងអាវ ប្រធានផ្នែកក៏រាយការណ៍

ទៅអ្នកចាត់ការទូទៅថាសន្តិសុខចាប់បានជាងម៉ាស៊ីនម្នាក់លួចក្បាលប៊ិចម៉ូទ័រ ចំនួន០១ បម្រុងយកចេញទៅក្រៅ ប៉ុន្តែសន្តិសុខមិនបានសួរនាំអ្វីច្រើនទេ ព្រោះដល់ម៉ោងកម្មករចេញពីធ្វើការ។ លុះស្អែកឡើងខាងរោងចក្របានឆែកកាមេរ៉ាសុវត្ថិភាពហើយ ឃើញឈ្មោះ **ឱ សំអុន** លួចក្បាលប៊ិចម៉ូទ័រពិតមែន។ បន្ទាប់ពីបានហៅមកសួរ ឈ្មោះ**ឱ សំអុន** បានសារភាព ទើបរោងចក្រដាក់ពាក្យបណ្ដឹងនៅប៉ុស្ដិ៍ ប៉ុស្តិ៍នគរបាលរដ្ឋបាលមហាឫស្សីតែម្ដង។ លុះនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង ១៥ រសៀល សមត្ថកិច្ចក៏បានមកដល់រោងចក្រ រកឃើញថាឈ្មោះ **ជា ចាន់** និងឈ្មោះ **ដួង សំណាង** មានការពាក់ព័ន្ធទៅនឹងករណីលួចសម្ភារៈក្នុងរោងចក្រ ខ្លួនក៏ដាក់ពាក្យបណ្ដឹងបន្ថែមលើឈ្មោះ **ឱ សំអុន**, ឈ្មោះ **ជា ចាន់** និងឈ្មោះ **ដួង សំណាង** តែម្ដង។ ខ្លួនសូមបញ្ជាក់បន្ថែមថា កន្លងមកឈ្មោះ **ឱ សំអុន**, ឈ្មោះ **ជា ចាន់** និងឈ្មោះ **ដួង សំណាង** ធ្លាប់បានលួចសម្ភារៈក្នុងរោងចក្រតែមិនមានភស្តុតាងច្បាស់ ទើបរោងចក្រមិនបានដាក់ពាក្យបណ្ដឹង។ សម្ភារៈដែលបាត់មានដូចជា៖ ក្បាលប៊ិចម៉ូទ័រ ចំនួន **៣៨២ គ្រាប់** ដោយតម្លៃក្បាលប៊ិចម៉ូទ័រក្នុងមួយគ្រាប់តម្លៃ **៥០ (ហាសិប) ដុល្លារអាមេរិក** ខ្សែភ្លើងមួយចំនួន និងម៉ាស៊ីនខ្យល់ចំនួន**០២ កន្លែង**។ ខ្លួនសំណូមពរឱ្យតុលាការផ្ដន្ទាទោសជនត្រូវចោទតាមច្បាប់។

តាមចម្លើយដើមបណ្ដឹងនេះ ឃើញថា ដើមបណ្ដឹងបានប្ដឹងលើឈ្មោះ **ជា ចាន់** និងឈ្មោះ **ដួង សំណាង** ដោយផ្អែកលើតែចម្លើយឈ្មោះ **ឱ សំអុន** តែមួយគត់ ដោយពុំមានភស្តុតាងជាមូលដ្ឋានផ្សេងឡើយ។

**៤**-ផ្អែកតាមអំណានចម្លើយសាក្សីឈ្មោះ **ឱ សំអុន** ថា កាលពីឆ្នាំ២០២២ ខ្លួន និងឈ្មោះ **ជាង ចេក** ធ្លាប់បានឃើញឈ្មោះ **ដួង សំណាង** និងឈ្មោះ **ជា ចាន់** លួចរបស់គេ ហើយខ្លួនក៏ដើរចេញទៅ ខ្លួនមិនបានដឹងថាពួកគេលួចរបស់គេលក់បានប៉ុន្មានទេ ពេលនោះគេចៀរម៉ាស៊ីនម៉ូទ័រយកស្ពាន់នៅខាងក្នុង ដោយមួយម៉ូទ័រមានស្ពាន់ទម្ងន់ប្រហែលមួយគីឡូក្រាម យកទៅលក់អេតចាយ។

ចម្លើយសាក្សីដែលបានបញ្ជាក់ថា ជនជាប់ចោទទាំងពីរបានលួចចៀរយកស្ពាន់ម៉ូទ័រនេះ គឺជាការប៉ាន់ស្មានរបស់សាក្សីរូបនេះប៉ុណ្ណោះ ព្រោះថាតាមចម្លើយជនជាប់ចោទឈ្មោះ **ជា ចាន់** ថាបានឃើញឈ្មោះ **ដួង សំណាង** ធ្វើការដោះម៉ូទ័រនៅក្នុងម៉ោងធ្វើការ និងស្ថិតនៅទីតាំងដែលជាងធ្វើការ ដែលជាសកម្មភាពរបស់ជាងធ្វើការធម្មតាប៉ុណ្ណោះ និងតាមចម្លើយដើមបណ្ដឹងខាងលើដែលបង្ហាញថា សម្ភារៈបាត់បង់ ពុំមានម៉ូទ័រ ឬស្ពាន់ម៉ូទ័រឡើយ។

**៥-តាមសំអាងហេតុខាងលើឃើញថា** ពុំមានអង្គហេតុលួចម៉ូទ័រ ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ **ជា ចាន់** និងឈ្មោះ **ដួង សំណាង** កើតឡើង កាលពីឆ្នាំ២០២២ នៅចំណុចរោងចក្រផលិតស្បែកជើង **វីង ស្តារស្ទិ** ស្ថិតនៅភូមិអង្គសុគន្ធា ឃុំមហាឫស្សី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ឡើយ។

**៦-តំណាងមហាអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖** ជនជាប់ចោទបានឆ្លើយចម្លើយដូចពីមុនមក មិនមានអ្វីប្រែប្រួលនោះទេ តំណាងមហាអយ្យការស្នើក្រុមប្រឹក្សាពិចារណាលើចម្លើយរបស់សាក្សីឈ្មោះ **ឱ សំអុន** ព្រោះហាក់និយាយបែបស្រមើស្រមៃគ្មានមូលដ្ឋាន និងភស្តុតាងច្បាស់លាស់ ហើយការចាប់ខ្លួន និងការដាក់ពន្ធនាគារលើជនណាមួយ គួរតែមានភស្តុតាងឱ្យបានត្រឹមត្រូវ ហើយក៏ស្នើក្រុមប្រឹក្សាពិចារណាលើចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ។ មួយវិញទៀត តើមានលិខិតផ្ទេរសិទ្ធិអំពីតំណាងក្នុងការឱ្យប្ដឹងដែរឬទេ ? ទោះបីជាការប្ដឹងនោះ

មិនបានទាមទារសំណងក៏ដោយ ប៉ុន្តែការប្ដឹងរបស់គាត់គឺធ្វើឱ្យគេរងគ្រោះ ហើយក្នុងចម្លើយរបស់ដើមបណ្ដឹង មិនមានភស្តុតាងច្បាស់ ព្រោះដើមបណ្ដឹងដឹងដោយសារចម្លើយរបស់ឈ្មោះ **ឱ សំអុន** ប៉ុណ្ណោះ ហើយការដាក់ពាក្យបណ្ដឹងនេះ គឺដាក់តាមចម្លើយរបស់ឈ្មោះ **ឱ សំអុន** ហើយដើមបណ្ដឹងបានបញ្ជាក់ពីការបាត់សម្ភារៈ មានដូចជាក្បាលប៊ិចម៉ូទ័រ ចំនួន៣៨២គ្រាប់ មានតម្លៃក្នុងមួយក្បាល៥០ដុល្លារ, ខ្សែភ្លើងមួយចំនួន, ម៉ាស៊ីនខ្យល់ ចំនួន២កន្លែង រីឯអង្គហេតុវិញ គឺបានរៀបរាប់ថា **"ធ្វើសកម្មភាពលួចស្ពាន់របស់រោងចក្រស្បែកជើង"** តើជាស្ពាន់អ្វី? ក្នុងពាក្យបណ្ដឹងសរសេរបញ្ជាក់អំពីការបាត់សម្ភារៈផ្សេងៗ តែពេលនៅក្នុងអង្គហេតុបែរជាសរសេរអំពីការបាត់ស្ពាន់ទៅវិញ ត្រង់ចំណុចនេះសូមក្រុមប្រឹក្សាពិចារណា។ ឃើញថា មិនមានភស្តុតាងណាមួយក្រៅពីសម្ដីរបស់ឈ្មោះ **ឱ សំអុន** នោះទេ ចំណែកឯដើមបណ្ដឹងមិនមានភស្តុតាងអ្វីទាល់តែសោះ ហើយចំពោះជនជាប់ចោទឈ្មោះ **ដួង សំណាង** ក៏ដូចគ្នាដែរ គឺមិនឃើញមានភស្តុតាងណាមួយឡើយក្នុងការចោទប្រកាន់។ ដូចនេះតំណាងមហាអយ្យការយល់ឃើញថា ពុំទាន់ឃើញមានភស្តុតាងណាមួយដែលបង្ហាញថាជនជាប់ចោទឈ្មោះ **ជា ចាន់** និងឈ្មោះ **ដួង សំណាង** បានប្រព្រឹត្តបទល្មើសនោះឡើយ ដោយសំអាងលើហេតុផល និងភស្តុតាងនៃការលើកឡើងខាងលើ តំណាងមហាអយ្យការស្នើក្រុមប្រឹក្សាពិនិត្យពិចារណាសម្រេច។

**សេចក្ដីសន្និដ្ឋាននេះ មានហេតុផលសមស្របតាមច្បាប់។**

៧-មេធាវី **សេង រាជ** ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ **ជា ចាន់** បានធ្វើសេចក្ដីសន្និដ្ឋានថាៈ ខ្លួនសូមឯកភាពទាំងស្រុងលើការសន្និដ្ឋានរបស់តំណាងមហាអយ្យការ និងសូមសំណូមពរដល់ក្រុមប្រឹក្សាមេត្តាបដិសេធចោលនូវសាលក្រមលេខ: ៧៧០ (ខ) ចុះ**ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤** របស់សាលាដំបូងខេត្តកំពង់ស្ពឺ និងសូមស្នើសុំក្រុមប្រឹក្សាមេត្តាដោះលែងកូនក្ដីខ្លួនឈ្មោះ **ជា ចាន់** ឱ្យមានសេរីភាពឡើងវិញ ព្រោះកូនក្ដីខ្លួនបានអនុវត្តទោសដល់សព្វថ្ងៃបាន **៦ខែ** មកហើយ នឹងត្រូវចប់នៅថ្ងៃទី១៨ **ខែសីហា ឆ្នាំ២០២៤** នេះផងដែរ។

**សេចក្ដីសន្និដ្ឋាននេះ មានហេតុផលសមស្របតាមច្បាប់។**

៨-មេធាវី **ស៊ាង រ៉ាឌី** ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ **ដួង សំណាង** បានធ្វើសេចក្ដីសន្និដ្ឋានថាៈ ចំពោះការចោទប្រកាន់មកលើកូនក្ដីខ្លួន គឺតំណាងមហាអយ្យការក៏បានលើកឡើងដែរថា មិនមានភស្តុតាងណាមួយបញ្ជាក់ថាកូនក្ដីខ្លួនបានប្រព្រឹត្តអំពើលួចនោះឡើយ ចំពោះធាតុផ្សំនៃបទល្មើស ក៏មិនមានធាតុផ្សំគ្រប់គ្រាន់ក្នុងការចោទប្រកាន់កូនក្ដីខ្លួនដែរ ហើយការសម្រេចរបស់តុលាការខេត្តកំពង់ស្ពឺ ហាក់មានភាពអយុត្តិធម៌មកលើកូនក្ដីខ្លួន ដូច្នេះ សូមស្នើសុំក្រុមប្រឹក្សាមេត្តាពិនិត្យពិចារណាសម្រេចលើសេចក្ដីសម្រេចរបស់តុលាការសាលាដំបូងខេត្តកំពង់ស្ពឺ ត្រង់ចំណុចទី១.១ និងចំណុចទី២ ព្រោះថាខាងដើមបណ្ដឹងមិនមានភស្តុតាងគ្រប់គ្រាន់ឡើយ ដោយផ្អែកតែលើចម្លើយរបស់សាក្សីឈ្មោះ **ឱ សំអុន** តែប៉ុណ្ណោះ យោងតាមមាត្រា **៣៨ នៃរដ្ឋធម្មនុញ្ញ** វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ដូច្នេះ សូមក្រុមប្រឹក្សាមេត្តាលើកលែងចោទប្រកាន់ និងសម្រេចបញ្ឈប់ដីកាចាប់ខ្លួនមកលើកូនក្ដីខ្លួន។

សេចក្តីសន្និដ្ឋាននេះ មានហេតុផលសមស្របតាមច្បាប់។

៩-ពុំមានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ ជា ចាន់ ពីបទ សមគំនិតក្នុងអំពើលួច ប្រព្រឹត្តនៅចំណុច រោងចក្រផលិតស្បែក ជើង វីង ស្តារស៊្វ ស្ថិតនៅភូមិអង្គសុគន្ធា ឃុំមហាឬស្សី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩, មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

១០-ពុំមានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ ដួង សំណាង ពីបទ លួច ប្រព្រឹត្តនៅចំណុច រោងចក្រផលិតស្បែកជើង វីង ស្តារស៊្វ ស្ថិតនៅភូមិអង្គសុគន្ធា ឃុំមហាឬស្សី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និង មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

១១-សាលក្រមព្រហ្មទណ្ឌលេខ: ៧៧០(ឧ) ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ដែលបានសម្រេចផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ ជា ចាន់ និងជនជាប់ចោទឈ្មោះ ដួង សំណាង ពុំត្រឹមត្រូវឡើយ គប្បីសភាព្រហ្មទណ្ឌបដិសេធចោល តាមមាត្រា ៤០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១២-ពុំមានភស្តុតាងណាមួយបញ្ជាក់ថា ជនជាប់ចោទឈ្មោះ ដួង សំណាង បានទទួលដីកាកោះហៅឱ្យចូលសវនាការនេះឡើយ ដូចនេះសាលដីកានេះ ជាសាលដីកាកំបាំងមុខជនជាប់ចោទដែលត្រូវទុកសិទ្ធិប្តឹងទាស់ និងប្តឹងសាទុក្ខតាមច្បាប់។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ: ១០៩ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៤ របស់មេធាវី ហម ស៊ុនរិទ្ធិ និងមេធាវី សេង រាជ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ជា ចាន់ ។

២-ទទួលបណ្តឹងឧទ្ធរណ៍លេខ:១១៧ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤ របស់ជនជាប់ចោទឈ្មោះ ដួង សំណាង ។

៣-បដិសេធសាលក្រមព្រហ្មទណ្ឌលេខ: ៧៧០ (ឧ) ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ។

៤-ឱ្យជនជាប់ចោទឈ្មោះ ជា ចាន់ រួចខ្លួនពីបទចោទប្រកាន់ ពីបទ សមគំនិតក្នុងអំពើលួច ប្រព្រឹត្តនៅចំណុចរោងចក្រផលិតស្បែក ជើង វីង ស្តារស៊្វ ស្ថិតនៅភូមិអង្គសុគន្ធា ឃុំមហាឬស្សី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩, មាត្រា ៣៥៣ និង មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៥-ឱ្យជនជាប់ចោទឈ្មោះ ដួង សំណាង រួចខ្លួនពីបទចោទប្រកាន់ ពីបទ លួច ប្រព្រឹត្តនៅចំណុច រោងចក្រផលិតស្បែកជើង វីង ស្តារស៊្វ ស្ថិតនៅភូមិអង្គសុគន្ធា ឃុំមហាឬស្សី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៦-បញ្ឈប់ការចាប់ខ្លួនជនជាប់ចោទឈ្មោះ ដួង សំណាង ។

-សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទឈ្មោះ ជា ចាន់,កំបាំងមុខជនជាប់ចោទឈ្មោះ ដួង សំណាង និងប្រកាសជាសាធារណៈ នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤។

-ទុកសិទ្ធិប្ដឹងទាស់ និងប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: អ៊ុច កែនបូ | ហត្ថលេខា: កែវ មុនី,យូ ប៊ុនណា | ហត្ថលេខា: ឌុច សុខសារិន |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃព្រហស្បតិ៍ ៣រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស២៥៦៨

សាលាឧទ្ធរណ៍ភ្នំពេញ,ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

**ឌុច សុខសារិន**

**ក្រឡាបញ្ជី**

**អ៊ុច កែនបូ**